**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តតាកែវ**

**គណៈកម្មាធិការលទ្ធកម្ម**

លេខៈ ............./ ២០១៦ សជណ-លកតក

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការដេញថ្លៃការងារជួសជុលផ្លូវក្រាលក្រួសក្រហម ប្រវែង២,០៥០ម៉ែត្រ ទទឹងខ្នងលើ០៥ម៉ែត្រ កម្រាស់០.២០ម៉ែត្រ ចិញ្ចើមសងខាង០១ម៉ែត្រ ដាក់លូភ្លោះ និងលូទោលកាត់ផ្លូវចំនួន០៥កន្លែង ជូនសាលាខេត្តតាកែវ

**ខេត្តតាកែវ** សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស(គិតទាំងសហគ្រាសឯកត្តបុគ្គល)ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា÷ **ខេត្តតាកែវ** នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការស្តីពីការងារជួសជុលផ្លូវក្រាលក្រួសក្រហមប្រវែង២,០៥០ម៉ែត្រ ទទឹងខ្នងលើ០៥ម៉ែត្រ កម្រាស់០,២០ម៉ែត្រ ចិញ្ចើមសង្ខាង០១ម៉ែត្រ និងដាក់លូកាត់ផ្លូវចំនួន០៥កន្លែង លូទោលមុខកាត់០,៦០ម៉ែត្រ ប្រវែង០៨ម៉ែត្រ ចំនួន០២កន្លែង , លូទោលមុខកាត់០១ម៉ែត្រ ប្រវែង០៨ម៉ែត្រ ចំនួន០២កន្លែង និងលូភ្លោះមុខកាត់០១ម៉ែត្រ ប្រវែង០៨ម៉ែត្រ ចំនួន០១កន្លែង (ស្ថិតនៅក្នុងភូមិសែនអោក ព្រំប្រទល់ឃុំត្រាំកក់ និងឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ )ជូនសាលាខេត្តតាកែវ។

**ខេត្តតាកែវ** បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ ។ឯកសារដេញថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្ត ដែលមានអាសយដ្ឋានស្ថិតនៅក្នុងសាលាខេត្តតាកែវ(ភូមិ២ សង្កាត់រកាក្នុង ក្រុងដូនកែវ) ចាប់ពីថ្ងៃទី២២..ខែមេសា..ឆ្នាំ២០១៦ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខៈ០៣២៩៣១ ២៧៣)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៦.... ខែ.ឧសភា...ឆ្នាំ២០១៦ វេលាម៉ោង.៩:០០......... ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង៩:០០... ថ្ងៃទី .២៦........ ខែ ..ឧសភា....... ឆ្នាំ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មខេត្តតាកែវ ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅខេត្តតាកែវ ថ្ងៃទី ៣..... ខែ...[illegible]..... ឆ្នាំ ២០១៦

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ឡាយ វណ្ណៈ**

**ចម្លងជូន**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- អង្គភាពប្រឆាំងអំពើពុករលួយ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ការិយាល័យលទ្ធកម្ម)
- ឯកសារ-កាលប្បវត្តិ